# ការិយាល័យ

# របស់

# ឧត្តមស្នងការ ទទួលបន្ទុកសិទ្ធិមនុស្ស

ការផ្តល់ជារបាយការណ៍ ដោយរដ្ឋ ជាភាគីទាំងឡាយ: .២៤-០២-៨៩. សារណាធិប្បាយ (ការកត់សំគាល់,វិភាគ និងបកស្រាយដោយហ្មត់ចត់បំផុត) លើ **សសសវ** សារណាធិប្បាយទូទៅទី១

(CESCR General Comment 1, General Comment 1)

## សារណាធិប្បាយទូទៅទី១

<u>ការផ្តល់ជារបាយការណ៍ ដោយរដ្ឋ ជាភាគីទាំងឡាយ</u>

(<u>សម័យប្រជុំលើក ទី៣</u>)*

១-កាតព្វកិច្ចក្នុងការផ្តល់ជារបាយការណ៍ ដែលមានចែងនៅក្នុងភាគទី ៤នៃកតិកាសញ្ញានោះ គឺធ្វើឡើងជាពិសេសសំរាប់ជួយ រដ្ឋជាភាគីក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យត្រូវនិងកតិកាសញ្ញានេះ,ហើយជាងនេះទៅទៀត គឺដើម្បីផ្តល់ជាមូលដ្ឋានដល់ក្រុមប្រឹក្សា,ដោយមានគណ:កម្មាធិការជាអ្នកជួយ,ដើម្បីបំពេញការទទួលខុសត្រូវរបស់ខ្លួនក្នុងការតាមដានមើលឱ្យរដ្ឋជាភាគីអនុវត្តតាមកាតព្វកិច្ចរបស់ពួកគេហើយធ្វើយ៉ាងណាឱ្យបានសំរេចនូវសិទ្ធិសេដ្ឋកិច្ច,សង្គមកិច្ចនឹងវប្បធម៌ ឱ្យសមស្របនឹងបទបញ្ញត្តិនៃកតិកាសញ្ញានេះ ។ គណ:កម្មាធិការ យល់ឃើញថា វាមិនជាការត្រឹមត្រូវទាល់តែសោះ ដែលសន្មតថា ការផ្តល់ជារបាយការណ៍នេះ គឺគ្រាន់តែជាការធ្វើឱ្យរួចពីដៃតែប៉ុណ្ណោះ ដែលតម្រូវតាមបែបបទដែលរដ្ឋនិមួយៗមានកាតព្វកិច្ចត្រូវធ្វើនូវរបាយការណ៍នេះ ដាក់ជូនឱ្យស្ថាប័នពាក់ព័ន្ធអន្តរជាតិខាងតាមដានមើល ។ ផ្ទុយទៅវិញ,ដោយអនុលោមតាមពាកពេចន៍ជាសារវន្ត នឹងស្មារតីនៃកាតិកាសញ្ញានោះ, ដំណើរការដែលរដ្ឋបានរៀបចំតាក់តែងហើយដាក់ជូននូវរបាយការណ៍នេះ ពិតជាអាចយកមកប្រើបានព្រមទាំងធ្វើឱ្យបានសំរេចនូវគោលដៅជាច្រើនយ៉ាងទៀត ។

២-<u>គោលដៅទី១,</u> ដែលមានភាពសមស្របទៅនឹងរបាយការណ៍ដំបូងដែលចាប់តាំងពីកតិកាសញ្ញានេះចាប់

ចូលជាធរមាន តម្រូវឱ្យរដ្ឋពាក់ព័ន្ធធ្វើ២ឆ្នាំម្តងនោះ,គឺដើម្បីធានាថា ការសើរើយ៉ាងសង្ខេប តែងាយយល់ ត្រូវបានគេធ្វើឡើងទាក់ទិនទៅនឹងនីតិកម្មជាតិ, បទបញ្ញត្តិរដ្ឋបាលនឹងនីតិវិធីនានាព្រមទាំងការប្រព្រឹត្តជាទំលាប់ផ្សេងៗ ក្នុងគោលបំណងធានាឱ្យមានការគោរពតាមកតិកាសញ្ញានេះឱ្យបានត្រឹមត្រូវជាទីបំផុត ។ ដើម្បីជាការឧទាហរណ៍ស្រួលយល់,គឺថា ការសើរើបែបនេះអាចត្រូវបានធ្វើឡើងព្រមៗគ្នា ជាមួយទីស្តីការរដ្ឋមន្ត្រីជាតិពាក់ព័ន្ធនិមួយៗឬអាជ្ញាធរទទួលខុសត្រូវខាងតាក់តែងនិងអនុវត្តគោលនយោបាយ ក្នុងវិស័យផ្សេងៗ ដែលកតិកាសញ្ញាត្រូវគ្របដណ្តប់-គឺមានយុត្តាធិការលើ ។

៣-<u>គោលដៅទី២</u> គឺដើម្បីធានាថាឱ្យរដ្ឋជាភាគីតាមដានមើលស្ថានភាពពិតប្រាកដ ដែលពាក់ព័ន្ធទៅនិងសិទ្ធិនិមួយៗនោះ ឱ្យបានជាប់ជានិច្ច,ធ្វើដូច្នេះ ខ្លួននិងបានដឹងច្បាស់ថា តើពលរដ្ឋម្នាក់ៗនៅក្នុងរដ្ឋឬនៅក្រោមយុត្តាធិការរបស់ខ្លួននោះ កំពុងបានទទួលឬនៅមិនទាន់ទទួលបាន នូវសិទ្ធិនិមួយៗនោះបានក៏រិតណាដែរ ។ បើតាមបទពិសោធន៍របស់គណៈកម្មាធិការមកទល់ពេលនេះនោះ បានឱ្យដឹងថាការធ្វើឱ្យបានសំរេចនូវគោលដៅនេះមិនស្ថិតនៅលើការខំតាក់តែងរៀបរៀងនូវស្ថិតិឬការប៉ាន់ស្មានជាតួលេខសារុបរបស់ជាតិនោះទេ, តែវាស្ថិតនៅលើការយកចិត្តទុកដាក់ជាពិសេសទៅលើដំបន់ ឬ មណ្ឌលដែលក្រីក្រជាងគេ ឬក៏ចំពោះក្រុមតូចៗណាមួយដែលហាក់ដូចជា ងាយស្រួលទទួលរងគ្រោះ ឬគ្មាននរណា រវីរវល់សោះនោះ ។ ដូច្នេះឯង,ជំហ៊ានដំបូងជាការចាំបាច់ដើម្បីឱ្យបានសំរេចចនូវសិទ្ធិសេដ្ឋកិច្ច,សង្គមកិច្ចនឹវប្បធម៌នោះគឺ ត្រូវធ្វើហេតុវិនិច្ឆ័យនិងស្វែងយល់នូវស្ថានភាពបច្ចុប្បន្ននេះឱ្យបានល្អសឹន ។ គណៈកម្មាធិការ ពិតជាយល់ដឹងថា ដំណើរការតាមដាននិងប្រមូលពតិមាននោះ គឺជាការងារស៊ីពេលវេលានិងអស់ប្រាក់កាសជាច្រើន, ដូច្នេះហើយបានជាកតិកាសញ្ញាប្រការទី២, កថាខ័ណ្ឌទី១ និង ប្រការទី ២២ និង ២៣បានចែងទុកថាវាជាការចាំបាច់ដែលត្រូវតែមានជំនួយនិងសហប្រតិបត្តិការអន្តរជាតិដើម្បីជួយរដ្ឋជាភាគីទាំងនោះបំបេញកាតព្វកិច្ចជាចាំបាច់របស់ខ្លួន ។ ប្រសិនបើមានករណីពិតដូច្នេះមែននោះ,ហើយរដ្ឋជាភាគីបានសំរេចចិត្តថាខ្លួនពិតជាគ្មានសមត្ថភាពដើម្បីអនុវត្តនូវដំណើរការតាមដានមើលដែលការនេះដែលជាភាគមួយទាំងស្រុងនៃដំណើរការនោះៗ, រៀបចំឡើងដើម្បីលើកតំកើងនូវគោលដៅដែលបានគ្រោងទុកមកហើយក្នុងគោលនយោបាយសធារណៈហើយនេះពិតជាករណីខានមិនបានជាដាច់ខាតក្នុងការអនុវត្តន៏ឱ្យមានប្រសិទ្ធិភាពនៃកតិកាសញ្ញានេះផងដែរ,រដ្ឋនេះឯងគួរតែសរសេរដាក់ចូលការពិតអស់ទាំងនេះទៅក្នុងរបាយការណ៏ឱ្យគណៈកម្មាធិការបានជ្រាបដោយត្រូវបង្ហាញនូវសារលក្ខណៈ（Nature） និងទំហំនៃជំនួយអន្តរជាតិដែលខ្លួនត្រូវការនោះ ។

៤-ក្នុងខណៈដែលថា ការតាមដានគឺធ្វើឡើងដើម្បីផ្តល់ជូននូវសព្វទស្សន៍(Overview)យ៉ាងពិស្តារនៃស្ថានភាពបច្ចុប្បន្ន នឹងអត្ថប្រយោជន៍ដ៏ចំបងនៃសព្វទស្សន៍បែបនេះនោះ គឺធ្វើឡើងដើម្បីផ្តល់ជូនជាមូលដ្ឋានសំរាប់រៀបរាប់ឱ្យបានពិស្តារនូវគោលនយោបាយទាំងឡាយដែលបានចែងទុកយ៉ាងច្បាស់លាស់ ថែមទាំងបានគូសបញ្ជាក់ទិសដៅដោយប្រុងប្រយ័ត្នទៀតផង, ដែលរួមបញ្ចូលនូវការកំណត់អាទិភាពផ្សេងៗ ដូចដែលបទបញ្ញត្តិនៃកតិកាសញ្ញានេះបានឆ្លុះឱ្យឃើញនោះឯង។ ដូច្នេះ, គោលដៅទី៣ នៃដំណើរការរធ្វើរបាយការណ៍នេះ គឺដើម្បីធ្វើឱ្យរដ្ឋាភិបាលអាចបង្ហាញចេញឱ្យឃើញថា ខ្លួនពិតជាបានចាប់ ផ្តើមធ្វើនូវគោលនយោបាយដ៏សំខាន់នោះហើយ។ ក្នុងខណៈដែលថា កតិកាសញ្ញាបានបញ្ជាក់នូវកាតព្វកិច្ចនេះឱ្យច្បាស់នៅក្នុងប្រការ ១៤ មានក្នុងករណីដែលថា "ការអប់រំថ្នាក់ បឋមសិក្សាត្រូវមានជាដាច់ខាតហើយមិនមានបង់ប្រាក់ទេ" នោះ, នៅមិនទាន់បានត្រូវគេធានាឱ្យមានជូនគ្រប់ៗគ្នានៅឡើយទេនោះ, កាតព្វកិច្ច ប្រៀបប្រដូចគ្នាមួយ " ដើម្បីរៀបចំឱ្យមានឡើងនិងអនុមត័ផែនការប្រតិបត្តិការដ៏ពិស្តារ ដើម្បីធ្វើយ៉ាងណាឱ្យមានការអនុវត្តន៏រីកចំរើនទៅមុខ ទៅលើសិទ្ធិណាមួយក្នុងចំណោមសិទ្ធិទាំងនោះ ដែលមានចែងនៅក្នុងកតិកាសញ្ញានេះ គឺពិតជាមានចែងនៅក្នុង ប្រការទី ២, ចំណុច ១ ថា " នឹងចាត់វិធានការ .......ដោយប្រើមធ្យោបាយសមស្របគ្រប់បែបយ៉ាង " ។

៥-គោលដៅទី៤ នៃដំណើរការផ្តល់របាយការណ៍ គឺធ្វើឡើងដើម្បីសំរួលដល់ ការតាមដានឃ្លាំមើលដោយសាធរណជន នូវគោលនយោបាយរដ្ឋាភិបាល ដែលពាក់ព័ន្ធនិងសិទ្ធិ សេដ្ឋកិច្ច,សង្គមកិច្ច, និងវប្បធម៌ ព្រមទាំងលើកទឹកចិត្ត នូវវិស័យទាំងឡាយខាងសេដ្ឋកិច្ច,សង្គមកិច្ចនិងវប្បធម៌ជាច្រើននៃសង្គម ឱ្យចូលពាក់ព័ន្ធក្នុងការរៀបចំតាក់តែង,ការអនុវត្តន៏និងពិនិត្យសើរើឡើងវិញនូវគោលនយោបាយអស់នោះ។ នៅពេលពិនិត្យរបាយការណ៏ដែលដាក់ជូនឱ្យ មកទល់ពេលនេះនោះ, គណៈកម្មាធិការសុំទទួលស្វាគមន៍ចំពោះការពិតដែលថាមានរដ្ឋជាច្រើន, ដែលបានឆ្លុះបញ្ចាំងឱ្យឃើញប្រព័ន្ធនយោបាយនិងសេដ្ឋកិច្ចខុសគ្នា, បានលើក ទឹកចិត្តឱ្យខាងក្រុមអង្គការក្រៅរដ្ឋាភិបាលផ្តល់ជូននូវប្រវេសនៈន័យ(Inputs) គឺទិន្នន័យជាយោបល់ប្រឹក្សាដើម្បីបញ្ចូលទៅក្នុងការរៀបចំតាក់តែងរបាយការណ៏របស់ពួកគេដោយអនុវត្តតាមកតិកាសញ្ញានេះ ។រដ្ឋខ្លះទៀតបានអះអាងថាខ្លួនបានចែករបាយការណ៏នេះយ៉ាងទូលំទូលាយឱ្យសាធារណជនទូទៅជ្រាបដើម្បីឱ្យពួកគេជួយបន្ថែមចូលនូវយោបល់ល្អៗ។ ដោយប្រើមធ្យោបាយបែបនេះ, ការរៀបរៀងតាក់តែងនូវរបាយការណ៏នេះព្រមទាំងការដែលប្រជាពលរដ្ឋគ្រប់ស្រទាប់បានជួយកែលំអបែបនេះ គឺពិតជា,

យ៉ាងហោចណាស់ ក៏បានក្លាយទៅជាអំពើមួយមានតម្លៃប្រហែលគ្នានិងការសន្ទនាគ្នាប្រកបដោយផ្លែផ្កា ដែលត្រូវបានធ្វើឡើងនៅថ្នាក់អន្តរជាតិ រវាងគណៈកម្មាធិការ និង អ្នកតំណាងទាំងឡាយ នៃរដ្ឋដែលបានធ្វើរបាយការណ៍នោះៗដែរ ។

៦-គោលដៅទី ៥ គឺធ្វើឡើងដើម្បី ផ្តល់ជូននូវមូលដ្ឋានមួយ សំរាប់ឱ្យរដ្ឋជាភាគីខ្លួនឯង ព្រមទាំងគណៈកម្មាធិការ អាចធ្វើការវាយតម្លៃយ៉ាងមានប្រសិទ្ធិភាព នូវវិសាលភាពនៃការរីកចំរើនដែលបានទទួល ដើម្បីធ្វើដំណើរឆ្ពោះទៅរកការបានធ្វើឱ្យសំរេចនូវកាតព្វកិច្ចដែលមានចែងនៅក្នុងកតិកាសញ្ញានេះ ។ ដើម្បីគោលបំណងនេះ, វាមានប្រយោជន៍ណាស់ដែលរដ្ឋនោះៗ ត្រូវចង្អុលបង្ហាញនូវចំណុចចាំបាច់បំផុតនៃគោលដៅទាំឡាយណា ដែលខ្លួនចង់ ឱ្យគេវាយតម្លៃតែក្នុងវិស័យដែលខ្លួនយល់ឃើញថាគួរតែធ្វើនោះ ។ ដើម្បីឱ្យជា ឧទាហរណ៏នោះ គឺដូចជាថា គេតែងតែយល់ឃើញជាទូទៅថា វាមានសារសំខាន់ណាស់ដែលគេត្រូវតែបញ្ជាក់ទិសដៅឱ្យបានច្បាស់លាស់ ទៅលើការកាត់បន្ថយមរណប្រមាណរបស់ទារក,ទៅលើវិសាលភាពនៃការចាក់ថ្នាំការពារកុមារ, ការផ្តល់ជូនឯកតាធាតុភ្លើងដោយការហូប-ចុក (Inputs of Calories) សំរាប់ម្នាក់ៗ, មានចំនួនមនុស្ស ប៉ុន្មាននាក់សំរាប់មណ្ឌលសុខភាពនិមួយៗ,។ល ។ មានវិស័យជាច្រើនក្នុងចំណោមវិស័យអស់ទាំងនោះ ដែលគេមិនត្រូវការប្រាប់ពីចំណុចចាំបាច់ទាំងនោះៗទេ, តែមានចំណុចចាំបាច់ពិសេសជាច្រើនទៀត ដែលអាចផ្តល់ជូន នូវមុខសញ្ញាសំខាន់ណាស់ ដើម្បីឱ្យមានការរីកចំរើន ។

៧-ចំពោះរឿងនេះ, គណៈកម្មាធិការសូមធ្វើការកត់សំគាល់ថា កតិកាសញ្ញានេះមានការយកចិត្តទុកជាពិសេសទៅលើគោលគំនិតថា "ការបានសំរេចបានជាបន្តៗគ្នា" នូវសិទ្ធិពាក់ព័ន្ធផ្សេងៗ,ហើយដោយសារមូលហេតុនេះឯង ទើបគណៈកម្មាធិការសូមធ្វើការលើកទឹកចិត្តដល់រដ្ឋជាភាគីទាំងអស់ ឱ្យដាក់ចូលទៅក្នុងរបាយការណ៏តាមកាលបរិច្ឆេទដែលបានកំរិតទុក នូវពត៌មានដែលនិងបង្ហាញឱ្យឃើញថា ការបានសំរេចដ៏ពិតប្រាកដជាបន្តៗគ្នា នូវសិទ្ធិពាក់ព័ន្ធផ្សេងៗនោះ ពិតជាមានការរីកចំរើនមែន ។ ដើម្បីឱ្យមាប្រសិទ្ធិភាពក្នុងរឿងនេះនោះ, វាជាការពិតប្រាកដណាស់ ដែលថាទិន្នន័យទាំងឡាយ--ទាំងផ្នែកគុណភាពនិងបរិមាណ--ត្រូវតែបានផ្តល់ជូនឱ្យមើល ដើម្បីធ្វើការវាយតម្លៃដែលត្រូវធ្វើទៅលើស្ថានការនោះ ឱ្យបានត្រឹមត្រូវ ។

៨-គោលដៅទី៦ គឺដើម្បីធ្វើយ៉ាងណាឱ្យរដ្ឋជាភាគីខ្លួនឯងនោះ បានយល់ឱ្យច្បាស់នូវបញ្ហាអស់នោះផង និង

គុណវិបត្តិផ្សេងៗផង ដែលខ្លួនបានជួបប្រទះ នៅក្នុងកិច្ចខំប្រឹងប្រែងរបស់ខ្លួនដើម្បីធ្វើយ៉ាងណាឱ្យបាន សំរេចជាបន្តបន្ទាប់គ្នាយ៉ាងពេញទំហឹង នូវសិទ្ធិសេដ្ឋកិច្ច,សង្គមកិច្ចនិងវប្បធម៌នោះៗ។ ហើយដោយសារ មូលហេតុនេះឯង ទើបវាជាការចាំបាច់ដែល រដ្ឋជាភាគីត្រូវតែរាយការណ៍ប្រាប់ឱ្យបានពិស្តារ នូវ "កត្តានិងការ លំបាកទាំងអស់នោះ" ដែលរារាំងនូវការបានសំរេចសិទ្ធិនោះៗ។ ដំណើរការរកឱ្យឃើញនិងស្គាល់ឱ្យបានច្បាស់ នូវការលំបាកដែលពាក់ព័ន្ធនោះ គឺពិតជានិងបានបង្កើតឱ្យមានជាក្របខ័ណ្ឌមួយ សំរាប់រៀបចំឱ្យមានគោល នយោបាយដ៏សមស្របផ្សេងៗជាច្រើន។

៩-<u>គោលដៅទី៧</u> គឺដើម្បីធ្វើយ៉ាងណា ឱ្យគណៈកម្មាធិការ និង រដ្ឋជាភាគីទាំងអស់គ្នាបានសម្រួលនូវការ ប្តូរនូវពត៌មានរវាងរដ្ឋទាំងអស់ ដើម្បីបង្កលក្ខណៈឱ្យមានការយោគយល់គ្នាកាន់តែប្រសើរឡើង ចំពោះ បញ្ហាដូចគ្នា ដែលរដ្ឋជាភាគីទាំងនោះបានជួបប្រទះ ព្រមទាំងការរិះរកដោយពេញចិត្តរួមគ្នា នូវមធ្យោបាយ ទាំងឡាយប្រភេទណា ដែលនិងត្រូវចាត់ឡើងដើម្បី ញ៉ាំងឱ្យមានការសំរេចបាននូវ សិទ្ធិណាមួយ ក្នុង ចំណោម សិទ្ធិទាំងឡាយ ដែលមានចែងក្នុងកតិកាសញ្ញានេះ។ ដំណើរការដែលបានចាត់ឱ្យមានឡើងបែប នេះនោះ គឺពិតជានិងធ្វើឱ្យ គណៈកម្មាធិការអាចរិះរកឱ្យឃើញ នូវមធ្យោបាយដ៏សមស្របជាទីបំផុតដែល ក្នុងនោះ សហគមន៍អន្តរជាតិ អាចជួយរដ្ឋផ្សេងៗបាន ដោយអនុលោមតាមប្រការ ២២និងប្រការ ២៣នៃ កតិកាសញ្ញានេះ។ ដើម្បី គូសបញ្ជាក់ឱ្យឃើញ នូវសារសំខាន់ ដែលគណៈកម្មាធិការនេះ មានការយកចិត្ត ទុកដាក់ ទៅលើគោលបំណងនេះនោះ, គណៈកម្មាធិការនិងនាំយកមកពិភាក្សាគ្នា នៅសម័យប្រជុំលើក ទី៤ នូវសារណាធិបាយ(Comments) ជាទូទៅដោយឡែក ទៅលើប្រការអស់នោះ។

- មាននៅក្នុងឯកសារ : E/1989/22